*សារព័ត៌មាន New York Times*

## ក្រុមហ៊ុនប្រេងប៊ីភី BP ធ្វើការទូទាត់ថ្លៃសង

រាយការណ៍ដោយJOE NOCERA (ថ្ងៃទី9 ខែមករា ឆ្នាំ2012)

ថ្ងៃនេះ ខ្ញុំនឹងជម្រាបអំពីរឿងល្អៗមួយចំនួនទាក់ទងទៅនឹងក្រុមហ៊ុនប្រេងប៊ីភី BP និងរឿងអាក្រក់មួយចំនួនទាក់ទងនឹងមេធាវី ដែលប្តឹងក្រុមហ៊ុនប្រេងប៊ីភី BP។ សូមមេត្តាកុំផុងកាហ្វេ។

គួរអោយរន្ធត់ដូចជាគ្រោះថ្នាក់នៅក្នុងតំបន់ទឹកជ្រៅ Deepwater Horizon បានកើតឡើងនៅខែមេសា ឆ្នាំ2010 — ដែលបានសំលាប់បុគ្គលិកទូកក្តោងនេសាទចំនួន 11 ក្នុងខណៈដែលប្រេងរាប់លានហ្គាឡុងបានហូរចូលទៅក្នុងតំបន់ឈូងសមុទ្រ Mexico — ក្រុមហ៊ុនប្រេងប៊ីភី BP បានបំពេញការងារដោយទទួលបានលទ្ធផលគួរអោយស្ងើចសរសើរ។ គ្មានការចំណាយទេនៅក្នុងយុទ្ធនាការបោសសំអាតប្រេង។ ក្រុមហ៊ុនបានទទួលថវិការចំនួន 1 លានដុល្លារ ដើម្បីស្តារបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរសមុទ្រឡើងវិញ។ ក្រុមហ៊ុនបានគាំទ្រយុទ្ធនាការដើម្បីលួងលោមទាក់ទាញភ្ញៀវទេសចរណ៍ត្រលប់មកតំបន់ឆ្នេរជាប់ឈូងសមុទ្រនេះឡើងវិញ។ ថ្ងៃនេះ រយះពេលជិតពីរឆ្នាំហើយបន្ទាប់ពីមានការធ្លាយប្រេង ឆ្នេរសមុទ្រកំពុងចាំងផ្លេកៗ អ្នកនេសាទភាគច្រើនកំពុងប្រកបរបរនេសាទ ហើយសណ្ឋាគារជាច្រើនក៏មានមនុស្សមកស្នាក់នៅពេញដែរ។

តាមរយះការជំរុញយ៉ាងខ្លាំងក្លារបស់ប្រធានាធិបតី Obama ក្រុមហ៊ុនប្រេងប៊ីភី BP បានយល់ព្រមបង្កើតមូលនិធិមួយមានចំនួន 20 កោដដុល្លាដើម្បីទូទាត់សងអ្នកណា ដែលអាចបង្ហាញថា ពួកគេបានទទួលរងផលវិបាកខាងផ្នែកសេដ្ឋកិច្ចដោយសារគ្រោះថ្នាក់នេះ។ លោក Ken Feinberg ជាអតីតអ្នកគ្រប់គ្រងនៃមូលនិធិទូទាត់សងសំណងជនរងគ្រោះនៅក្នុងទូកក្តោងនេសាទចំនួន 11 គ្រឿងកាលពីខែកញ្ញាត្រូវបានគេកំណត់អោយមានទំនួលខុសត្រូវទៅលើស្ថាប័នសម្របសម្រួលពាក្យបណ្តឹងសម្រាប់តំបន់ឆ្នេរជាប់ឈូងសមុទ្រ ដូចដែលគេបានស្គាល់។ មកដល់ឥឡូវ លោក Feinberg បានទូទាត់សំណងចំនួន 6.3 កោដដុល្លារ ទៅអោយអ្នកទាមទារសំណងប្រហែលជា 200,000 ករណី។ លោក Daniel Becnelជាមេធាវីម្នាក់ដែលដោះស្រាយពាក្យបណ្តឹងរាប់ពាន់ករណី មានប្រសាសន៍ថា ភ្ញៀវរបស់គាត់តែងតែទទួលបានប្រាក់ច្រើនជាងពីលោក Feinberg បើធៀបទៅនឹងអ្វីដែលពួកគេទទួលបាន ប្រសិនបើពួកគេដាក់ប្តឹងទៅតុលាការ។ "លោកមិនអាចបំពេញការងារអោយប្រសើរជាងលោក Feinberg ធ្លាប់បានធ្វើទេ" លោក Becnel មានប្រសាសន៍។

ដើម្បីចាត់ការវាក្នុងវិធីមួយផ្សេងទៀត ស្ថាប័នសម្របសម្រួលពាក្យបណ្តឹងសម្រាប់តំបន់ឆ្នេរជាប់ឈូងសមុទ្រមានដំរើសប្រកបដោយប្រសិទ្ធិភាពគួរអោយ

កត់សំគាល់មួយចំពោះការខូចខាតដែលកើតឡើង
ពោលគឺត្រូវបានគេវាស់ស្ទង់ជាញឹកញយក្រោយពេលមានគ្រោះថ្នាក់រួមនេះៈ ឧទាហរណ៏
ធ្វើការប្រៀបធៀបវាជាមួយគ្រោះមហន្តរាយ Exxon Valdez ឆ្នាំ1989 នៅ Alaska
ដែលគ្រោះមហន្តរាយនេះបានចំណាយពេលដោះស្រាយក្នុងតុលាការជិតពីរទសវត្សន៏ក្នុងការតទល់ជាមួយដើមចោទដើម្បីទទួលបានប្រាក់សំណងចុងក្រោយចំនួន 1.3 កោដដុល្លារ។

ដូច្នេះ ចំនុចរួមរបស់មូលនិធិតំបន់ឆ្នេរជាប់ឈូងសមុទ្រគឺរក្សាករណីក្តីទាំងនេះនៅក្រៅតុលាការ ហើយត្រលប់មករកការទូទាត់សងវិញ
អ្នកទាមទារសំណងត្រូវតែយល់ព្រមមិនប្តឹងតវ៉ាទៅលើការខូចខាតផ្សេងទៀត។
មានរឿងជាច្រើនថាវាត្រឹមត្រូវទៅតាមនិន្នាការនេះទេ។ ជនរងគ្រោះមិនត្រូវរង់ចាំអស់រយះពេលជាច្រើនឆ្នាំ — ឬច្រើនទសវត្សន៏ — ដើម្បីទទួលប្រាក់របស់ពួកគេឡើយ។
ត្រូវតែលុបបំបាត់ចោលនូវភាពមិនជឿជាក់ទៅលើក្តីវិវាទ។ ជនរងគ្រោះទទួលរងការខូចខាតជារូបិយវត្ថុ ដូចដែលពួកគេចង់បាន ប្រសិនបើពួកគេឈ្នះក្តី ប៉ុន្តែគ្មានការចំណាយទៅលើពាក្យបណ្តឹងទេ។
ពួកគេក៏បានចំណាយតិចតួចទៅលើថ្លៃឈ្នួលផ្នែកច្បាប់ដែរ។ ហើយប្រសិនបើពួកគេមិនចង់បង់ថ្លៃឈ្នួលនេះទេ មិនអីទេ ពួកគេនៅតែអាចប្តឹងបាន។ ដូចដែលគេប្រសាសន៏ថា វាគឺជាយុទ្ធសាស្រ្តឈ្នះៗមួយ។

លើកលែងតែមានវត្តមានសម្រាប់ក្រុមមេធាវីដើមក្តីណាមួយដែលកំពុងជួយសម្រួលការប្តឹងទាមទារសំណងប្រឆាំងទៅនឹងក្រុមហ៊ុនប្រេងប៊ីភី BP។ ពួកគេមានប្រសាន៏ថាពួកគេទទួលបានករណីបណ្តឹងលើសពី100,000 ករណីថ្វីបើគ្មានករណីបណ្តឹងណាទាមទារសំណងជាទឹកប្រាក់ច្រើនក៏ដោយ
ដូចជាករណីកម្មករទទួលរងគ្រោះថ្នាក់ជាដើម លោក Feinberg ក៏បានដោះស្រាយជូនទាំងអស់។ ជាច្រើនខែ មេធាវីទាំងនេះបានរៀបចំ "ការកាត់សេចក្តីទៅលើបំណុល," ថ្មីៗនេះបានចុះកាលបរិច្ឆេទនៅចុងខែកុម្ភះ។

ទោះជាយ៉ាងណាក៏ដោយ ការកាត់សេចក្តីនេះត្រូវបានបិទ វាគឺជាការងារឥតប្រយោជន៏ដ៏ធំធេងមួយៈ
ក្រុមហ៊ុនប្រេងប៊ីភី BP បានយល់ព្រមទៅលើបំណុលរួចជាស្រេចហើយ ដែលការយល់ព្រមនេះបានសងក្នុងចំនួន 20 កោដដុល្លារ។ ការចង់បានរបស់មេធាវីមិនអាចទទួលបានប្រាក់ច្រើនជាងនោះទេ
វាដូចជានៅឆ្ងាយបើតុលាការនឹង ផ្តល់ជូន។ ការសងជម្ងឺចិត្តមិនអាចធ្វើឡើងដោយគ្មានហេតុផលទេៈ
ច្បាប់សហព័ន្ធបង្ការអ្នកទាមទារសំណងស្ទើតែទាំងអស់ពីការទាមទារសងសងជម្ងឺចិត្ត។ ទេ
មានហេតុផលតែមួយគត់ គឺរឿងវិវាទត្រូវតែបានកើតឡើង។ មេធាវីចង់ទទួលបានប្រភេទថ្លៃឈ្នួលច្រើន
ដែលអាចទទួលបានពីបណ្តឹងធំៗប៉ុណ្ណោះ។ បាទ និន្នាការរបស់លោក Feinberg
កំពុងបង្ហាញអោយឃើញថាមានប្រជាប្រិយភាពចំពោះអ្នកទាមទារសំណង
ដែលករណីច្រើនក្នុងចំណោមករណីរបស់ពួកគេបានដោះស្រាយ។

ដូច្នេះនេះគឺជាអ្វីដែលពួកគេបានអនុវត្ត។ ពួកគេបានទៅជួបចៅក្រមសហព័ន្ធដែលគ្រប់គ្រងពាក្យបណ្តឹងរបស់ក្រុមហ៊ុនប្រេងប៊ីភី BP ហើយស្នើសុំអោយបង្កើតមាន "មូលនិធិបម្រុង" មួយដែលនឹងបង្កើតឡើងសម្រាប់ 6 ភាគរយនៃអ្នកទាមទារសំណងនៅពេលអនាគត ដែលបានដោះស្រាយដោយលោក Feinberg។ (ពួកគេក៏ចង់បាន 4 ភាគរយពីការខូចខាតមួយចំនួននៅក្នុងរដ្ឋ Alabama និង រដ្ឋ Louisiana ដែលទទួលបានដែរ។) ចៅក្រម Carl Barbier — អតីតមេធាវីដើមចោទ ខ្លួនគាត់ផ្ទាល់— បានយល់ព្រមអនុវត្តដោយគ្មានអង្គសាវនាការជំនុំជំរះ។ ចុងក្រោយ មូលនិធិបម្រុងមួយចំនួន ឬមូលនិធិទាំងអស់នឹងត្រូវបានប្រើប្រាស់ក្នុងការចំណាយទៅអោយមេធាវី។ ត្រឹមត្រូវហើយៈ ពួកគេកំពុងព្យាយាម យកថ្លៃឈ្នួលពីភ្ញៀវដែលពួកគេមិនដែលធ្វើជាអ្នកតំណាងអោយនោះ។ គួរអោយឆ្ងល់។ (ពេលថ្មីៗនេះ ចៅក្រម Barbier បានដាកបន្តិចមកវិញពីគោលការណ៏របស់គាត់ និងកំពុងអនុញ្ញាតិអោយភាគីទាំងពីរបំពេញឯកសារសង្ខេបដែលផុតកំណត់នៅថ្ងៃព្រហស្បត៏។)

នៅពេលខ្ញុំបានសាកសួរ ថាតើពួកគេអាចកែតម្រូវការយកថ្លៃឈ្នួលនេះពីភ្ញៀវបានដូចម្តេចដែរ គេបានប្រាប់ខ្ញុំថាបណ្តឹងរបស់ពួកគេគឺជាហេតុផលចំបងមួយ ដែលលោក Feinberg នឹងមានឆន្ទះសោកស្តាយដល់ថវិការបស់ក្រុមហ៊ុនប្រេងប៊ីភី BP។ ប៉ុន្តែលោក Tony Buzbeeជាមេធាវីម្នាក់ទៀតដែលបានដោះស្រាយពាក្យបណ្តឹងទាមទារសំណងជាច្រើនតាមរយៈមូលនិធិ សូមបន្ថយអារម្មណ៏នៅពេលខ្ញុំបានប្រាប់គាត់ដូច្នោះ។ "រហូតមកដល់ពេលនេះ ពួកគេមិនបានអនុវត្តអ្វីមួយដែលបានផ្តល់ជាផលប្រយោជន៏មកដល់ភ្ញៀវរបស់ខ្ញុំឡើយ" គាត់បានមានប្រសាសន៏។ "ភ្ញៀវរបស់ខ្ញុំបានជ្រើសរើសយក មិនមែនជាផ្នែកមួយនៃថ្លៃឈ្នួលរបស់ពួកគេឡើយ។ នៅលើលោកនេះ ហេតុអ្វីបានពួកគេគួរតែត្រូវទូទាត់អោយខ្លួនពួកគេអញ្ចឹង?"

វាគឺជាសំណួរគួរអោយចាប់អារម្មណ៏មួយដែរ។ ស្ថាប័នសម្របសម្រួលពាក្យបណ្តឹងទាមទារសំណងសម្រាប់តំបន់ឆ្នេរជាប់ឈូងសមុទ្រមានសក្តានុពលដើម្បីបម្រើជូនជាគំរូមួយសម្រាប់ការដោះស្រាយគ្រោះថ្នាក់មានលក្ខណៈជាឧស្សាហកម្មនាពេលអនាគត។ វាគឺជាមោទនភាពថា គេអាចទូទាត់សងសំណងដល់ជនរងគ្រោះយ៉ាងឆាប់រហ័ស ហើយមានតម្លាភាពដោយមិនគិតថ្លៃឈ្នួលបណ្តឹង និងកំហុសឆ្គងកន្លងមក។ ប៉ុន្តែ ចំពោះការកើតឡើងនេះ វាមិនមែនចំពោះតែក្រុមហ៊ុនដែលត្រូវតែទាមទារយកលាបសក្ការៈរបស់គេនោះទេ។ ដូច្នេះចុះមេធាវីផ្សេងៗទៀតវិញ។

*******************************